សេចក្តី ប្រកាសពត៌មាន

## ស្តីពីតួរលេខថ្មី អំពី អត្រាអ្នកផ្ទុកមេរោគអេដស៍ នៅកម្ពុជា

របស់

មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ នៃ ក្រសួងសុខាភិបាល

កាលពីសប្តាហ៍មុន មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ បានរៀបចំកិច្ចប្រជុំក្រុមអ្នកជំនាញថ្នាក់ជាតិ និង អន្តរជាតិ ដើម្បីធ្វើការប៉ាន់ស្មាន អំពីអត្រាអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា។ នេះជាកិច្ចប្រជុំលើកទីបួន ហើយចាប់តាំងពីឆ្នាំ ១៩៩៨ មក។

ក្រុមអ្នកជំនាញបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗដែលសកលលោកកំពុងតែប្រើប្រាស់ ហើយបូករួមនឹងទិន្នន័យពីប្រភពផ្សេងៗរបស់ប្រទេសកម្ពុជា ដើម្បីគណនាអត្រាអ្នកផ្ទុកមេរោគអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន។ ការប៉ាន់ស្មាននេះ ត្រូវបានធ្វើឡើងអោយកាន់តែប្រសើរជាងមុនដោយសារ យើងមាននូវឧបករណ៍ និង ការសន្មត់ថ្មីៗ។ វិធីសាស្ត្រសំរាប់ធ្វើការប៉ាន់ស្មាន អំពីអត្រាអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជានៅពេលនេះ គឺបានបូករួមបញ្ចូលទាំងឥទ្ធិពលនៃការផ្តល់ថ្នាំប្រឆាំងនឹងមេរោគអេដស៍ផងដែរ។

ក្រុមអ្នកជំនាញបានយល់ស្របទាំងអស់គ្នាថា អត្រាអ្នកផ្ទុកមេរោគអេដស៍ក្នុងចំនោមប្រជាជនអាយុពី ១៥ ទៅ ៤៩ឆ្នាំ នៅកម្ពុជាក្នុងឆ្នាំ ២០១០ គឺ ០.៨ភាគរយ។ អត្រានេះគឺមានការធ្លាក់ចុះជាបន្តបន្ទាប់ពី ២.៤ភាគរយ កាលពីឆ្នាំ១៩៩៨។ ការធ្លាក់ចុះនេះ គឺបណ្តាលមកពីការធ្លាក់ចុះនូវការឆ្លងជំងឺអេដស៍ថ្មី។ ក្នុងកំឡុងបួនទៅប្រាំឆ្នាំចុងក្រោយនេះ អត្រានៃការធ្លាក់ចុះមានសភាពយឺតជាងមុន ព្រោះមានការធ្លាក់ចុះនូវអត្រាស្លាប់របស់អ្នកជំងឺអេដស៍ ដោយសារមានការកើនឡើងយ៉ាងគំហុកនៃការគ្របដណ្តប់របស់សេវាផ្តល់ថ្នាំប្រឆាំងនឹងមេរោគអេដស៍ ដល់អ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា។

កម្ពុជានឹងប្រើប្រាស់តួរលេខថ្មី អំពីអត្រាអ្នកផ្ទុកមេរោគអេដស៍នេះ ដើម្បីធ្វើការប៉ាន់ស្មាននូវផលប៉ះពាល់របស់ការរីករាលដាលមេរោគអេដស៍ដែលនឹងកើតមានឡើងនៅបណ្តាឆ្នាំខាងមុខរួមមានៈ ចំនួនអ្នកផ្ទុកមេរោគអេដស៍ ចំនួនអ្នកដែលត្រូវការថ្នាំប្រឆាំងនឹងមេរោគអេដស៍ នឹងចំនួនអ្នកដែលស្លាប់ដោយសារជំងឺអេដស៍។ នៅក្នុងកំឡុងប៉ុន្មានខែខាងមុខ យើងនឹងបន្តធ្វើការងារប៉ាន់ប្រមាណអំពីការវិវត្តរបស់ការរាលដាលនៃមេរោគអេដស៍ និង តំរូវការនាពេលអនាគតទាំងនេះ ។